ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១២៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើវិសោធនកម្ម មាត្រា ៧ ជំពូកទី ៣ នៃអនុក្រឹត្យលេខ ១៣អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ១៣អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងតាមសភាពការណ៍ចាំបាច់

## សំរេច

មាត្រា ១ .-

ត្រូវបានធ្វើវិសោធនកម្មមាត្រា ៧ ជំពូកទី ៣ នៃអនុក្រឹត្យលេខ ១៣អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា ដែលមានខ្លឹមសារដូចតទៅ :

"មាត្រា ៧ ថ្មី : នាយកដ្ឋានពាហិរសាសនា ទទួលបន្ទុក :

- ត្រួតពិនិត្យអង្គការសាសនាផ្សេងៗ ដែលសុំដាក់ទីតាំង និងធ្វើសកម្មភាព នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ណែនាំព្រះវិហារពាហិរសាសនាទាំងអស់ ឱ្យគោរពម៉ឺងម៉ាត់តាមគម្ពីរធម៌វិន័យ របស់សាសនារៀងៗខ្លួន ឱ្យបានត្រឹមត្រូវតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា
- ណែនាំបរិស័ទគ្រប់និកាយសាសនា សាមគ្គីចូលរួមកសាងប្រទេសជាតិ មាតុភូមិ និងឱ្យចេះគោរពសិទ្ធិនៃជំនឿរបស់ពលរដ្ឋ
- ពិនិត្យ និងលើកយោបល់លើសំណើសុំការអនុញ្ញាតឱ្យបើកវិហារនៃសាសនាផ្សេងៗ ឬបិទសកម្មភាព ព្រះវិហារនោះ បើពិនិត្យឃើញថា មិនគោរពតាមលក្ខន្តិកៈរបស់ខ្លួន ធ្វើឱ្យប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ និងច្បាប់របស់រដ្ឋ
- គ្រប់គ្រងស្ថិតិព្រះវិហារ ទីស្នាក់ការថ្វាយបង្គំ និងបរិស័ទ ផ្នែកពាហិរសាសនា
- ពិនិត្យ និងលើកយោបល់លើសំណើសុំការសាងសង់ និងសំណង់ព្រះវិហារ ឬការផ្លាស់ប្តូរទីកន្លែង
- លើកយោបល់លើការសុំពន្យារទិដ្ឋាការស្នាក់នៅរបស់សាសនិកបរទេស
- រៀបចំកិច្ចព្រមព្រៀង សហប្រតិបត្តិការអន្តរជាតិ ខាងវិស័យសាសនាផ្សេងៗ
- ធ្វើអធិការកិច្ចសាសនាគ្រប់ព្រះវិហារ ។"

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ